លឹម ផល្គុន និង សែន ពិសិដ្ឋ

បរិញ្ញាបត្រគណិតវិទ្យា និង ពាណិជ្ជកម្ម

គណិតវិទ្យាជុំវិញពិភពលោក

សម្រាប់សិស្សពូកែគណិតវិទ្យា

$$\frac{a^2b(b-c)}{a+b}+\frac{b^2c(c-a)}{b+c}+\frac{c^2a(a-b)}{c+a}\geq 0$$

BMO 2010

ភាគ៦

អារម្ភកថា

សួស្តី ប្រិយមិត្តអ្នកសិក្សាជាទីគោរព រាប់អាន !

សៀវភៅគណិតវិទ្យាជុំវិញពិភពលោក ដែលអ្នកសិក្សាកំពុងកាន់នៅក្នុងដៃនេះ ខ្ញុំបាទបានរៀបរៀងឡើងក្នុងគោលបំណងទុកជាឯកសារស្រាវជ្រាវសម្រាប់អ្នកសិក្សាដែលមានបំណងក្លាយជាសិស្សពូកែផ្នែកគណិតវិទ្យា និង ដើម្បីត្រៀមប្រឡងប្រជែងនានា ។ រាល់លំហាត់ទាំងអស់នៅក្នុងសៀវភៅនេះ សុទ្ធសឹងតែជាប្រធានលំហាត់ដែលធ្លាប់បានចេញប្រឡងសិស្សពូកែគណិតវិទ្យារួចហើយនៅជុំវិញពិភពលោក និង ធ្លាប់ចេញប្រឡងប្រកួតប្រជែងគណិតវិទ្យាអូឡាំពិចអន្តរជាតិ (International Mathematical Olympiad) ដែលយើងខ្ញុំបានខិតខំស្រាវជ្រាវតាមរយះ Internet យកមកធ្វើដំណោះស្រាយយ៉ាងផ្ចិតផ្ចង់ ហើយព្រមទាំងក្បោះក្បាយបំផុត ។

ទោះជាយ៉ាងណាក៏ដោយ សៀវភៅនេះពុំមែនជាសៀវភៅដែលល្អហួសគេហួសឯងនោះទេ កំហុសឆ្គងដោយអចេតនាប្រាកដជាកើតមាន ទាំងបច្ចេកទេស និង អក្ខរាវិរុទ្ធ ។ អាស្រយ័ហេតុនេះយើងខ្ញុំជាអ្នករៀបរៀង រងចាំជានិច្ចនូវរាល់មតិរិះគន់បែស្ថាបនាពីសំណាក់អ្នកអានក្នុងគ្រប់មជ្ឈដ្ឋានដោយក្តីរីករាយបំផុត ដើម្បីកែលំអរសៀវនេះឱ្យកាន់តែមានសុក្រត្យភាពថែមទៀត ។

ជាទីបញ្ចប់ យើងខ្ញុំអ្នកនិពន្ធ សូមគោរពជូនពរចំពោះអ្នកសិក្សាទាំងអស់ជួបតែសំណាងល្អ និង ទទួលជោគជ័យជានិច្ចក្នុងឆាកជីវិត ។

បាត់ដំបងថ្ងៃទី ២៧ កក្កដា ឆ្នាំ២០១០

អ្នកនិពន្ធ និង ស្រាវជ្រាវ ***លឹម ផល្គុន***

Tel : 017 768 246

គណៈកម្មការនិពន្ធ និង រៀបរៀង

លោក លឹម ផល្គុន

លោក សែន ពិសិដ្ឋ

គណៈកម្មការត្រួតពិនិត្យបច្ចេកទេស

លោក លឹម ឆុន

លោក អ៊ឹង សំណាង

លោកស្រី ទុយ វីណា

លោក ទិត្យ ម៉េង

លោក នន់ សុខណា

លោក ព្រឹម សុនិត្យ

គណៈកម្មការត្រួតពិនិត្យអក្ខរាវិរុទ្ធ

លោក លឹម មិត្តសិរ

ការិយកុំព្យូទ័រ

លោក អ៊ឹង សំណាង

កញ្ញា លី គុណ្ណាកា

រចនាជំព័រ និង ក្រប

លោក ព្រុំ ម៉ាឡា

PROBLEMS

ភាគ៦

1. គេឱ្យ x, y, z ជាបីចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់ $xyz = 1$ ។

ចូរបង្ហាញវិសមភាព :

$$\frac{(x+y-1)^2}{z} + \frac{(y+z-1)^2}{x} + \frac{(z+x-1)^2}{y} \geq x+y+z$$

2. គេឱ្យត្រីកោណ ABC មួយ ។ មេដ្យាននៃត្រីកោណដែលគូសចេញពីកំពូល A , B , C កាត់រង្វង់ចារឹកក្រៅត្រីកោណរៀងគ្នាត្រង់ M , N , P ។

ចូរបង្ហាញថា $AM^2 + BN^2 + CP^2 \geq \frac{4}{3}(AB^2 + BC^2 + CA^2)$ ។

3.គេឱ្យអនុគមន៍ f ដែលចំពោះគ្រប់ចំនួនពិត $x \neq 0$ គេមានទំនាក់ទំនង ។

$f(x) - 2xf(\frac{1}{x}) = x^2 - \frac{2}{x} - 3$ ។ ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a, b, c

ចូរបង្ហាញថា $\frac{f(a)}{b} + \frac{f(b)}{c} + \frac{f(c)}{a} \geq 12$?

4.គេឱ្យអនុគមន៍ f ដែលចំពោះគ្រប់ចំនួនពិត $t \in IR$ គេមានទំនាក់ទំនង ។

$f\left(\frac{1-t^2}{1+t^2}\right) + t.f\left(\frac{2t}{1+t^2}\right) = 1$ ។ ចូរកំនត់រកអនុគមន៍ $y = f(x)$?

5.គេឱ្យអនុគមន៍ $f(t) = (t)^{\ln^2 t + 3\ln t + 3}$ ដែល $t > 0$ និង $t \neq 1$ ។

គេពិនិត្យស្វីតនៃចំនួនពិត (u_n) កំណត់ដោយ $u_1 = f(e)$ និងចំពោះគ្រប់ចំនួនគត់វិជ្ជមាន n គេមាន $u_{n+1} = f(u_n)$ ។

ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ចូរស្រាយថា $1 + \ln u_{n+1} = (1 + \ln u_n)^3$

រួចទាញរកតួ u_n ជាអនុគមន៏នៃ n ។

6.កំណត់គ្រប់ចំនួនគត់វិជ្ជមាន a , b , c ដើម្បីឱ្យបណ្តាសមីការខាងក្រោម

$$\begin{cases} x^2-2ax+b=0 \\ x^2-2bx+c=0 \\ x^2-2cx+a=0 \end{cases}$$ មានឬសជាចំនួនគត់វិជ្ជមាន ។

7.គេឱ្យ M ជាទីប្រជុំទម្ងន់នៃត្រីកោណ ABC ។

បើបន្ទាត់ AB ប៉ះទៅនឹងរង្វង់ចារឹកក្រៅនៃត្រីកោណ AMC នោះបង្ហាញថា

$\sin\angle CMA+\sin\angle\sin CBM\le\frac{2}{\sqrt{3}}$ ។

8.គេឱ្យត្រីកោណ ABC មានជ្រុង a , b , c និងមានមុំក្នុង α , β , γ

បើ $\alpha=3\beta$ ចូរបង្ហាញថា $(a-b)(a^2-b^2)=bc^2$?

9.គេឱ្យត្រីកោណ ABC មួយមានជ្រុង a , b , c ។

D , E, F ជាជើងកម្ពស់គូសចេញពីកំពូល A , B , C រៀងគ្នា ។

តាង $AD=h_a$, $BE=h_b$, $CF=h_c$ ជារង្វាស់កម្ពស់នៃត្រីកោណ

និង $HA=q_A$, $HB=q_B$, $HC=q_c$ ដែល H ជាអរតូសង់ត្រីកោណ ។

ចូរស្រាយថា $h_aq_a+h_bq_b+h_cq_c=\frac{a^2+b^2+c^2}{2}$ ។

10.ចូរកំណត់គ្រប់ចំនួនគត់វិជ្ជមាន x , y , z បើគេដឹងថា

$$\frac{13}{x^2}+\frac{1996}{y^2}=\frac{z}{1997}$$ ។

11.គេឱ្យ a,b,c ជាចំនួនពិតវិជ្ជមាន ។

ចូរបង្ហាញថា :

$$\frac{a^2b(b-c)}{a+b}+\frac{b^2c(c-a)}{b+c}+\frac{c^2a(a-b)}{c+a}\geq 0$$

(BMO 2010)

12.គេឱ្យ $a , b , c > 0$ ដែល $abc \geq 1$ ។

ចូរបង្ហាញថា $(1+\frac{a^2}{1+a})(1+\frac{b^2}{1+b})(1+\frac{c^2}{1+c}) \geq \frac{27}{8}$?

13.គេឱ្យត្រីកោណសមង្ស័ ABC មួយមាន G ជាទីប្រជុំទម្ងន់ ។

D ជាចំនុចមួយនៃ $[AB]$ ដែល $AD = AG$ ។

បន្ទាត់ DG កាត់ AC និង BC ត្រង់ E និង F រៀងគ្នា ។

ចូរបង្ហាញថា $ED = EF$ ។

14. គេឱ្យ a, b , c ជាបីចំនួនពិតវិជ្ជមាន ។ ចូរបង្ហាញថា :

$$\frac{a^5+b^5+c^5-(a+b+c)^5}{a^3+b^3+c^3-(a+b+c)^3}\geq\frac{10}{9}(a+b+c)^2$$

15.គេឱ្យស្ទីតចំនួនពិត (a_n) កំណត់ដោយ ៖

$a_0 = 4$, $a_1 = 9$ និង $a_{n+2} = 6a_{n+1} - 8a_n + 3$ ដែល $n = 0 , 1 , 2 , ...$

ចូរស្រាយថា a_n ជាការេប្រាកដចំពោះគ្រប់ $n \geq 0$ ។

16.គេឱ្យត្រីកោណ ABC មួយ ។ ចូរកំណត់តម្លៃអប្បបរមានៃ ៖

$$T = \frac{\cos^2\frac{A}{2}\cos^2\frac{B}{2}}{\cos^2\frac{C}{2}} + \frac{\cos^2\frac{B}{2}\cos^2\frac{C}{2}}{\cos^2\frac{A}{2}} + \frac{\cos^2\frac{C}{2}\cos^2\frac{A}{2}}{\cos^2\frac{B}{2}}$$

(Vietnam Team Selection Tests 2007)

17.គណនាផលបូក $S_n = \frac{1^3}{2} + \frac{2^3}{2^2} + \frac{3^3}{2^3} + ... + \frac{n^3}{2^n}$

រួចទាញរកលីមីតនៃ S_n កាលណា $n \to +\infty$ ។

18.គេឱ្យអនុគមន៍ f កំណត់ដោយ $f(n+1) - 2f(n) = \frac{n.2^{n+1}}{(n+1)!}$ គ្រប់ $n \in IN$

និង $f(o) = 1$ ។ គណនាលីមីត $\lim\limits_{n\to+\infty} [\frac{f(n)}{2^n}]$?

19.ចំពោះគ្រប់ចំនួនពិត $x \in (0 , \frac{\pi}{4})$

ចូរបង្ហាញថា $(\cos x)^{\cos x} > (\sin x)^{\sin x}$

20.គេឱ្យ D និង E ជាចំណុចនៅលើជ្រុង AB និង CA នៃត្រីកោណ ABC ដោយដឹងថា DE ស្របទៅនឹង BC ហើយ DE ប៉ះទៅនឹងរង្វង់ចារឹកក្នុងត្រីកោណ ABC ។ ចូរបង្ហាញថា $DE \le \frac{AB+BC+CA}{8}$

(Italy 1999)

21. គេឱ្យ a , b , c , d ជាបីចំនួនពិតដែលផ្ទៀងផ្ទាត់វិសមភាព :

$(a^2+b^2-1)(c^2+d^2-1) > (ac+bd-1)^2$

ចូរបង្ហាញថា $a^2+b^2>1$ និង $c^2+d^2>1$ ។

22.គេឱ្យ a , b , c ជាបីចំនួនពិតវិជ្ជមានដែល $\sqrt{ab}+\sqrt{bc}+\sqrt{ca}=1$ ។

ចូរកំនត់តម្លៃអប្បបរមានៃកន្សោម $E=\frac{a^2}{a+b}+\frac{b^2}{b+c}+\frac{c^2}{c+a}$ ។

23. ចូរគណនាផលបូក :

$$S_n=\frac{2}{3+1}+\frac{2^2}{3^2+1}+.....+\frac{2^{n+1}}{3^{2^n}+1}$$

24. គេឱ្យ $A=\frac{1}{1.2}+\frac{1}{3.4}+\frac{1}{4.5}+....+\frac{1}{1997.1998}$

និង $B=\frac{1}{1000.1998}+\frac{1}{1001.1997}+\frac{1}{1002.1996}+....+\frac{1}{1998.1000}$

ចូរបង្ហាញថា $\frac{A}{B}$ ជាចំនួនគត់ ?

25. គេឱ្យ x និង y ជាចំនួនគត់ដោយដឹងថា

$$x^3 + y^3 + (x+y)^3 + 30xy = 2000$$

ចូរបង្ហាញថា $x + y = 10$ ។

26.គេឱ្យ $x_1, x_2, ..., x_n$ (ដែល $n \geq 2$) ជាចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់ :

$$\frac{1}{x_1+1998} + \frac{1}{x_2+1998} + ... + \frac{1}{x_n+1998} = \frac{1}{1998}$$

ចូរបង្ហាញថា $\frac{\sqrt[n]{x_1.x_2...x_n}}{n-1} \geq 1998$ ។

27.គេឱ្យ x, y, z ជាបីចំនួនពិតវិជ្ជមានដែល $xyz = x + y + z$ ។

ចូរស្រាយថា $\frac{x+y}{1+z^2} + \frac{y+z}{1+x^2} + \frac{z+x}{1+y^2} \geq \frac{27}{2xyz}$ ។

28. ត្រីកោណមួយមានរង្វាស់ជ្រុងជាចំនួនគត់វិជ្ជមានហើយចារឹកក្រៅរង្វង់មួយមាន រង្វាស់កាំស្មើ 1 ។ ចូរកំណត់ជ្រុងនៃត្រីកោណនេះ រួចបង្ហាញថាវាមានមុំមួយស្មើ 90^o ។

29. ចូរបង្ហាញថាបើ $abc = 8$ និង $a, b, c > 0$ នោះគេបាន :

$$\frac{a^2}{\sqrt{(1+a^3)(1+b^3)}} + \frac{b^2}{\sqrt{(1+b^3)(1+c^3)}} + \frac{c^2}{\sqrt{(1+c^3)(1+a^3)}} \geq \frac{4}{3}$$

30.គេឱ្យត្រីកោណ ABC មួយមានជ្រុង $BC = a$, $AC = b$, $AB = c$ ហើយ

មានមុំក្នុងជាមុំស្រួច ។

ចូរស្រាយថា $\frac{a+b}{\cos C} + \frac{b+c}{\cos A} + \frac{c+a}{\cos B} \geq 4(a+b+c)$

31.គេឱ្យ $x\,,\,y\,,\,z>0$ ដែល $x+y+z=1$ ។

ចូរស្រាយថា $\frac{x^3}{(1-x)^2}+\frac{y^3}{(1-y)^2}+\frac{z^3}{(1-z)^2}\ge\frac{1}{4}$

32. គេឱ្យ a,b,c,d ជាចំនួនពិតវិជ្ជមានដែល $abcd=1$ ។

បើគេដឹងថា $a+b+c+d>\frac{a}{b}+\frac{b}{c}+\frac{c}{d}+\frac{d}{a}$ នោះចូរបង្ហាញថា

$a+b+c+d<\frac{b}{a}+\frac{c}{b}+\frac{d}{c}+\frac{a}{d}$ ។

33.គេយក $a\,,\,b\,,\,c$ ជាចំនួនវិជ្ជមានដែលផ្ទៀងផ្ទាត់ $abc=1$ ។

ចូរបង្ហាញថា $\frac{a}{(a+1)(b+1)}+\frac{b}{(b+1)(c+1)}+\frac{c}{(c+1)(a+1)}\ge\frac{3}{4}$

（Czech and Slovak Republics 2005 ）

34.គេយក $a\,,\,b\,,\,c$ ជាចំនួនវិជ្ជមាន។

ចូរបង្ហាញថា $(1+\frac{a}{b})(1+\frac{b}{c})(1+\frac{c}{a})\ge 2(1+\frac{a+b+c}{\sqrt[3]{abc}})$

（APMO 1998 ）

35.គេយក $a\,,\,b\,,\,c$ ជាចំនួនពិតនៃចន្លោះ $(0,1)$ ។

ចូរបង្ហាញថា $\sqrt{abc}+\sqrt{(1-a)(1-b)(1-c)}<1$

（Romania 2002 ）

36.ចូរគណនាផលបូក ៖

$$S_n=\frac{2}{3+1}+\frac{2^2}{3^2+1}+.....+\frac{2^{n+1}}{3^{2^n}+1}$$

37.គេយក a , b , c ជាចំនួនពិតវិជ្ជមានដែល $ab+bc+ca=abc$

ចូរបង្ហាញថា $\dfrac{a^4+b^4}{ab(a^3+b^3)}+\dfrac{b^4+c^4}{bc(b^3+c^3)}+\dfrac{c^4+a^4}{ca(c^3+a^3)}\geq 1$

（Poland 2006 ）

38.គេយក x , y , z ជាចំនួនពិតវិជ្ជមានដែល $xyz=1$

ចូរបង្ហាញថា $\dfrac{1}{yz+z}+\dfrac{1}{zx+x}+\dfrac{1}{xy+y}\geq\dfrac{3}{2}$

（Kazakhstan 2008 ）

39.ចំនួនពិត $a,$, b , c , x , y , z ផ្ទៀងផ្ទាត់ $a\geq b\geq c>0$ និង $x\geq y\geq z>0$

ចូរបង្ហាញថា

$$\frac{a^2x^2}{(by+cz)(bz+cy)}+\frac{b^2y^2}{(cz+ax)(cx+az)}+\frac{c^2z^2}{(ax+by)(ay+bx)}\geq\frac{3}{4}$$

（Korea 2000 ）

40.ចូរបង្ហាញថា $\dfrac{x}{1-x}+\dfrac{y}{1-y}+\dfrac{z}{1-z}\geq\dfrac{3\sqrt[3]{xyz}}{1-\sqrt[3]{xyz}}$

ចំពោះគ្រប់ $0<x$, y , $z<1$ ។

（Ireland 2002 ）

41. ចូរបង្ហាញថាចំពោះគ្រប់ a , b , c ជាចំនួនពិតវិជ្ជមានគេបាន :

$$\frac{a}{\sqrt{a^2+8bc}}+\frac{b}{\sqrt{b^2+8ca}}+\frac{c}{\sqrt{c^2+8ab}}\geq 1$$

（IMO 2001 ）

42. ចូរបង្ហាញថាចំពោះគ្រប់ a , b , c ជាចំនួនពិតវិជ្ជមានគេបាន :

$$\frac{(a+1)(b+1)^2}{3\sqrt[3]{c^2a^2}+1}+\frac{(b+1)(c+1)^2}{3\sqrt[3]{a^2b^2}+1}+\frac{(c+1)(a+1)^2}{3\sqrt[3]{b^2c^2}+1}\geq a+b+c+3$$

(Bulgaria 2007)

43.គេឱ្យ x , y , z ជាចំនួនពិតវិជ្ជមានដែល $\sqrt{x}+\sqrt{y}+\sqrt{z}=1$ ។

ចូរស្រាយថា :

$$\frac{x^2+yz}{\sqrt{2x^2(y+z)}}+\frac{y^2+zx}{\sqrt{2y^2(z+x)}}+\frac{z^2+xy}{\sqrt{2z^2(x+y)}}\geq 1$$

(APMO 2007)

44. បើចំនួនពិតវិជ្ជមាន a , b , c ផ្ទៀងផ្ទាត់ $a^2+b^2+c^2=3$ នោះចូរបង្ហាញថា :

$$\frac{a^2}{2+b+c^2}+\frac{b^2}{2+c+a^2}+\frac{c^2}{2+a+b^2}\geq\frac{(a+b+c)^2}{12}$$

(Baltic 2008)

45.គេមានចំនួនពិតវិជ្ជមាន a , b , c ផ្ទៀងផ្ទាត់ $a+b+c=1$ ។

ចូរបង្ហាញថា $\dfrac{a-bc}{a+bc}+\dfrac{b-ca}{b+ca}+\dfrac{c-ab}{c+ab}\leq\dfrac{3}{2}$ ។

(Canada 2008)

46. បើ a , b , c ជា ចំនួនពិតវិជ្ជមានផ្ទៀងផ្ទាត់ $ab+bc+ca=3$ ។

ចូរបង្ហាញថា $\dfrac{1}{1+a^2(b+c)}+\dfrac{1}{1+b^2(c+a)}+\dfrac{1}{1+c^2(a+b)}\leq\dfrac{1}{abc}$ ។

(Romania 2008)

47.គេឱ្យ a, b, c ជា ចំនួនពិតវិជ្ជមាន។

ចូរបង្ហាញថា $\frac{1}{a^2+bc}+\frac{1}{b^2+ca}+\frac{1}{c^2+ab}\le\frac{1}{2}(\frac{1}{ab}+\frac{1}{bc}+\frac{1}{ca})$ ។

(Lithuania 2006)

48.ចំពោះគ្រប់ចំនួនពិត a វិជ្ជមាន ឬសូន្យចូរបង្ហាញថា :

$(a+1)^{a+2}\ge e^{2a}$ ដែល $e = 2.7182$ ។

49.គេឱ្យផលបូក $S_n=\frac{1}{n^2}\sum_{k=1}^{n}\left[k\cos(\frac{k\pi}{n^2})\right]$

ក. បង្ហាញថា $\cos x\ge 1-\frac{x^2}{2}$ ចំពោះគ្រប់ $x\ge 0$ ។

ខ. គណនាលីមីត $\lim_{n\to+\infty}S_n$ ។

50.គេឱ្យអនុគមន៍ $f(n)=(n^2+n+1)^2+1$

តាង $u_n=\frac{f(1)f(3)f(5)....f(2n-1)}{f(2)f(4)f(6)....f(2n)}$; $n\in IN^*$

ចូរគណនាលីមីត $\lim_{n\to+\infty}(n\sqrt{u_n})$

51. គេឱ្យស្វ៊ីត (x_n) មួយកំណត់ដោយ :

$x_1=3$; $x_{n+1}=x_n{}^2-3x_n+4$ ចំពោះគ្រប់ $n\ge 1$ ។

ក. ចូរបង្ហាញថា $x_n\ge n+2$ ចំពោះគ្រប់ $n\ge 1$ ។

ខ. តាង $y_n=\sum_{k=1}^{n}\left(\frac{1}{x_k-1}\right)$ ចំពោះគ្រប់ $n\ge 1$ ។ គណនាលីមីត $\lim_{n\to+\infty}y_n$ ។

52. គេឱ្យស្វ៊ីត (x_n) មួយកំណត់ដោយ ៖

$$x_1 = a \;;\; x_{n+1} = \frac{x_n{}^2}{b} + x_n \;,\; a > 0 \;,\; b > 0$$ ចំពោះគ្រប់ $n \ge 1$ ។

ចូរគណនាលីមីត $\lim\limits_{n\to+\infty} \sum\limits_{k=1}^{n} \left(\frac{x_k}{x_{k+1}} \right)$ ។

53. គេឱ្យស្វ៊ីត (x_n) មួយកំណត់ដោយ ៖

$$x_n = \sqrt{a + \sqrt{a + \sqrt{a + ... + \sqrt{a}}}}$$ (មាន n រ៉ាឌីកាល់ និង $a > 0$)

ចូរស្រាយបញ្ជាក់ថា $x_n < \frac{1 + \sqrt{1 + 4a}}{2}$

54. គេឱ្យស្វ៊ីត (x_n) មួយកំណត់ដោយ ៖

$$x_n = \frac{1}{\sqrt{n^3}} \sum_{k=1}^{n} \left[k.\ln(1 + \frac{k}{\sqrt{n^3}}) \right]$$

ក.ចូរស្រាយបញ្ជាក់ថា $x - \frac{x^2}{2} \le \ln(1 + x) \le x$ ចំពោះគ្រប់ $x \ge 0$ ។

ខ.គណនាលីមីត $\lim\limits_{n\to+\infty} \left(x_n \right)$?

55. គេឱ្យត្រីកោណ ABC មួយមានជ្រុង $BC = a$, $AC = b$, $AB = c$ ។

AA' , BB' , CC' ជាកំពស់ ហើយ H ជាអរតូសង់ នៃត្រីកោណ ABC ។

ចូរស្រាយថា $a + b + c \ge 2\sqrt{3}(HA' + HB' + HC')$

56. គេឱ្យa , b , c , d ជាចំនួនពិតវិជ្ជមាន ។

$$S = \frac{a^4}{(a+b)(a^2+b^2)} + \frac{b^4}{(b+c)(b^2+c^2)} + \frac{c^4}{(c+d)(c^2+d^2)} + \frac{d^4}{(d+a)(d^2+a^2)}$$

ចូរបង្ហាញថា $S \geq \frac{a+b+c+d}{4}$ ។

57.បង្ហាញថា $n^3+(n+1)^3+(n+2)^3$ ជាពហុគុណនៃ 9 ចំពោះគ្រប់ $n \in IN^*$

58. គេឱ្យអនុគមន៍ $f(x)=2^x(ax^2+bx+c)$

រក a , b , c ដែល $f(x+1)-f(x)=2^x x^2$ រួចទាញរកផលបូក :

$$S_n = 2.1^2+2^2.2^2+2^3.3^2+....+2^n.n^2$$

59.គេឱ្យពហុធា $P(x)=2x^4+ax^2+bx+c$

កំណត់ a , b,c ជាចំនួនពិតដោយដឹងថា $P(x)$ ចែកដាច់នឹង $x-2$ ហើយ $P(x)$ ចែកនឹង x^2-1 សល់ x ។

60. គេឱ្យស៊េរីអនន្ត $\sum_{n=1}^{\infty}\left(\frac{1}{n^2}\right)=\frac{1}{1^2}+\frac{1}{2^2}+\frac{1}{3^2}+....+\frac{1}{n^2}$

ចូរស្រាយថាស៊េរីខាងលើនេះជាស៊េរីបង្រួម ។

61. ចូរកំណត់គ្រប់ចំនួនគត់វិជ្ជមាន m និង n ដែលផ្ទៀងផ្ទាត់សមីការ $3.2^m+1=n^2$

62. គេឱ្យP ជាចំណុចមួយនៅក្នុងត្រីកោណ ABC ។បន្ទាត់ AP,BP និង CP កាត់រង្វង់(Γ) ដែលចារឹកក្រៅត្រីកោណ ABC ម្តងទៀតត្រង់ K , L និង M រៀងគ្នា ។បន្ទាត់ប៉ះរង្វង់ (Γ) ត្រង់ C កាត់បន្ទាត់ AB ត្រង់ S ។ ឧបមាថា $SC=SP$ ។ ចូរបង្ហាញថា $MK=ML$

(IMO 2010)

63. គេឱ្យចំនួនពិតវិជ្ជមាន $x_1, x_2, ..., x_n$ ហើយគេតាង

$S_n = x_1 + x_2 + ... + x_n$ ។ ចូរស្រាយថា :

$$(1+x_1)(1+x_2)....(1+x_n) \le 1 + S + \frac{S^2}{2!} + ... + \frac{S^n}{n!}$$

(APMO 1989)

SOLUTION

ភាគ៦

លំហាត់ទី១

គេឱ្យ x, y, z ជាបីចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់ $xyz = 1$ ។

ចូរបង្ហាញវិសមភាព :

$$\frac{(x+y-1)^2}{z} + \frac{(y+z-1)^2}{x} + \frac{(z+x-1)^2}{y} \geq x+y+z$$

ដំណោះស្រាយ

បង្ហាញវិសមភាព :

$$\frac{(x+y-1)^2}{z} + \frac{(y+z-1)^2}{x} + \frac{(z+x-1)^2}{y} \geq x+y+z$$

របៀបទី១

តាមវិសមភាព $AM - GM$ គេបាន :

$$\frac{(x+y-1)^2}{z} + z \geq 2|x+y-1| \geq 2(x+y-1) \quad (1)$$

$$\frac{(y+z-1)^2}{x} + x \geq 2|y+z-1| \geq 2(y+z-1) \quad (2)$$

$$\frac{(z+x-1)^2}{y} + y \geq 2|z+x-1| \geq 2(z+x-1) \quad (3)$$

បូកវិសមភាព (1) , (2), (3) អង្គនឹងអង្គគេបាន :

$$\frac{(x+y-1)^2}{z} + \frac{(y+z-1)^2}{x} + \frac{(z+x-1)^2}{y} \geq 3(x+y+z) - 6$$

ដោយ $x+y+z \geq 3\sqrt[3]{xyz}=3$ ព្រោះ $xyz=1$

គេបាន $2(x+y+z)\geq 6$

ឬ $2(x+y+z)-6\geq 0$

ឬ $3(x+y+z)-6\geq x+y+z$

ដូចនេះ $\frac{(x+y-1)^2}{z}+\frac{(y+z-1)^2}{x}+\frac{(z+x-1)^2}{y}\geq x+y+z$

របៀបទី២

គេតាង

$$T=\frac{(x+y-1)^2}{z}+\frac{(y+z-1)^2}{x}+\frac{(z+x-1)^2}{y}-(x+y+z)$$

ដោយប្រើវិសមភាព $\frac{x^2}{a}+\frac{y^2}{b}+\frac{z^2}{c}\geq\frac{(x+y+z)^2}{a+b+c}$ គេបាន

$$T\geq\frac{\left[|x+y-1|+|y+z-1|+|z+x-1|\right]^2}{x+y+z}-(x+y+z)$$

$$T\geq\frac{(x+y-1+y+z-1+z+x-1)^2-(x+y+z)^2}{x+y+z}$$

$$T\geq\frac{(2x+2y+2z-3)^2-(x+y+z)^2}{x+y+z}$$

$$T\geq\frac{3(x+y+z-3)(x+y+z-1)}{x+y+z}$$

តាមវិសមភាព AM – GM គេមាន ៖

$x+y+z \geq 3\sqrt[3]{xyz} = 3$ (ព្រោះ $xyz = 1$)

គេទាញបាន $x+y+z-3 \geq 0$ និង $x+y+z-1 \geq 2$

ហេតុនេះ $T = \frac{3(x+y+z-3)(x+y+z-1)}{x+y+z} \geq 0$ ពិត

ដូចនេះ $\frac{(x+y-1)^2}{z} + \frac{(y+z-1)^2}{x} + \frac{(z+x-1)^2}{y} \geq x+y+z$ ។

លំហាត់ទី២

គេឱ្យត្រីកោណ ABC មួយ ។ មេដ្យាននៃត្រីកោណដែលគូសចេញពីកំពូល A , B , C កាត់រង្វង់ចារឹកក្រៅត្រីកោណរៀងគ្នាត្រង់ M , N , P ។

ចូរបង្ហាញថា $AM^2 + BN^2 + CP^2 \geq \frac{4}{3}(AB^2 + BC^2 + CA^2)$ ។

ដំណោះស្រាយ

បង្ហាញថា $AM^2 + BN^2 + CP^2 \geq \frac{4}{3}(AB^2 + BC^2 + CA^2)$



តាង a , b , c ជាជ្រុងត្រីកោណABC

ហើយ m_a , m_b , m_c ជារង្វាស់មេដ្យាន

គូសពីកំពូល A , B , C ។

យើងមាន $\angle ABC = \angle AMC$

(មុំស្កាត់ដោយធ្នូររួម AC)

ហើយ $\angle AA'B = \angle MA'C$ (មុំទល់កំពូល)

គេទាញបាន AA'B និង MA'C ជាត្រីកោណដូចគ្នា ។

គេបាន $\frac{AA'}{CA'} = \frac{A'B}{A'M} \Rightarrow A'M = \frac{A'B.CA'}{AA'} = \frac{a^2}{4m_a}$

ហើយ $AM = AA' + A'M = m_a + \frac{a^2}{4m_a}$

ស្រាយដូចគ្នាដែរ $BN = m_b + \frac{b^2}{4m_b}$ និង $CP = m_c + \frac{c^2}{4m_c}$ ។

តាង $T = AM^2 + BN^2 + CP^2$

$$T = (m_a + \frac{a^2}{4m_a})^2 + (m_b + \frac{b^2}{4m_b})^2 + (m_c + \frac{c^2}{4m_c})^2$$

$$= {m_a}^2 + {m_b}^2 + {m_c}^2 + \frac{a^2 + b^2 + c^2}{2} + \frac{1}{16}\left(\frac{a^4}{{m_a}^2} + \frac{b^4}{{m_b}^2} + \frac{c^4}{{m_c}^2}\right)$$

ដោយ ${m_a}^2 + {m_b}^2 + {m_c}^2 = \frac{3}{4}(a^2 + b^2 + c^2)$

គេបាន $T = \frac{5}{4}(a^2 + b^2 + c^2) + \frac{1}{16}\left(\frac{a^4}{{m_a}^2} + \frac{b^4}{{m_b}^2} + \frac{c^4}{{m_c}^2}\right)$

តាមវិសមភាព Cauchy – Schwart គេបាន

$$\frac{a^4}{{m_a}^2} + \frac{b^4}{{m_b}^2} + \frac{c^4}{{m_c}^2} \geq \frac{(a^2 + b^2 + c^2)^2}{{m_a}^2 + {m_b}^2 + {m_c}^2} = \frac{4}{3}(a^2 + b^2 + c^2)$$

គេទាញបាន ៖

$$T \geq \frac{5}{4}(a^2 + b^2 + c^2) + \frac{1}{12}(a^2 + b^2 + c^2) = \frac{4}{3}(a^2 + b^2 + c^2)$$

ដូចនេះ $AM^2 + BN^2 + CP^2 \geq \frac{4}{3}(AB^2 + BC^2 + CA^2)$ ។

លំហាត់ទី៣

គេឱ្យអនុគមន៍ f ដែលចំពោះគ្រប់ចំនួនពិត $x \neq 0$ គេមានទំនាក់ទំនង ។

$f(x) - 2x f(\frac{1}{x}) = x^2 - \frac{2}{x} - 3$ ។ ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a, b, c

ចូរបង្ហាញថា $\frac{f(a)}{b} + \frac{f(b)}{c} + \frac{f(c)}{a} \geq 12$?

ដំណោះស្រាយ

បង្ហាញថា $\frac{f(a)}{b} + \frac{f(b)}{c} + \frac{f(c)}{a} \geq 12$

គេមាន $f(x) - 2x f(\frac{1}{x}) = x^2 - \frac{2}{x} - 3$ ដែល $x \neq 0$

ជំនួស x ដោយ $\frac{1}{x}$ គេបាន $f(\frac{1}{x}) - \frac{2}{x} f(x) = \frac{1}{x^2} - 2x - 3$

គេបានប្រព័ន្ធសមីការ $\begin{cases} f(x) - 2x f(\frac{1}{x}) = x^2 - \frac{2}{x} - 3 \\ f(\frac{1}{x}) - \frac{2}{x} f(x) = \frac{1}{x^2} - 2x - 3 \end{cases}$

ឬ $\begin{cases} f(x) - 2x f(\frac{1}{x}) = x^2 - \frac{2}{x} - 3 \\ 2x f(\frac{1}{x}) - 4 f(x) = \frac{2}{x} - 4x^2 - 6x \end{cases}$

បូកសមីការពីរនេះគេបាន $-3 f(x) = -3x^2 - 6x - 3$

គេទាញបាន $f(x) = x^2 + 2x + 1 = (x+1)^2$

គេមាន $\frac{f(a)}{b}=\frac{(a+1)^2}{b}\geq\frac{4a}{b}$ ព្រោះ $a+1\geq 2\sqrt{a}$ ។

ហើយ $\frac{f(b)}{c}=\frac{(b+1)^2}{c}\geq\frac{4b}{c}$ និង $\frac{f(c)}{a}=\frac{(c+1)^2}{a}\geq\frac{4c}{a}$

គេបាន $\frac{f(a)}{b}+\frac{f(b)}{c}+\frac{f(c)}{a}\geq 4(\frac{a}{b}+\frac{b}{c}+\frac{c}{a})$

តាមវិសមភាព $AM-GM$ គេមាន $\frac{a}{b}+\frac{b}{c}+\frac{c}{a}\geq 3\sqrt[3]{\frac{a}{b}.\frac{b}{c}.\frac{c}{a}}=3$

ដូចនេះ $\frac{f(a)}{b}+\frac{f(b)}{c}+\frac{f(c)}{a}\geq 12$ ។

លំហាត់ទី៤

គេឱ្យអនុគមន៍ f ដែលចំពោះគ្រប់ចំនួនពិត $t\in IR$ គេមានទំនាក់ទំនង ។

$f\left(\frac{1-t^2}{1+t^2}\right)+t.f\left(\frac{2t}{1+t^2}\right)=1$ ។ ចូរកំនត់រកអនុគមន៍ $y=f(x)$?

ដំណោះស្រាយ

កំនត់រកអនុគមន៍ $y=f(x)$

គេមាន $f\left(\frac{1-t^2}{1+t^2}\right)+t.f\left(\frac{2t}{1+t^2}\right)=1 \quad (1)$

តាង $t=\tan\frac{x}{2}$ ដែល $x\neq(2k+1)\pi$, $k\in Z$

គេបាន $\cos x=\frac{1-t^2}{1+t^2}$, $\sin x=\frac{2t}{1+t^2}$

ទំនាក់ទំនង (1) អាចសរសេរ $f(\cos x)+\tan\frac{x}{2}.f(\sin x)=1 \quad (i)$

ជំនួស x ដោយ $\frac{\pi}{2}-x$ ក្នុង (i) គេបាន :

$$f(\sin x)+\tan(\frac{\pi}{4}-\frac{x}{2})f(\cos x)=1$$

$$f(\sin x)+\frac{1-\tan\frac{x}{2}}{1+\tan\frac{x}{2}}f(\cos x)=1$$

$$\frac{1+\tan\frac{x}{2}}{1-\tan\frac{x}{2}}f(\sin x)+f(\cos x)=\frac{1+\tan\frac{x}{2}}{1-\tan\frac{x}{2}}\quad \text{(ii)}$$

ធ្វើផលដកសមីការ (i) និង (ii) គេបាន :

$$(\tan\frac{x}{2}-\frac{1+\tan\frac{x}{2}}{1-\tan\frac{x}{2}})f(\sin x)=1-\frac{1+\tan\frac{x}{2}}{1-\tan\frac{x}{2}}$$

$$-\frac{1+\tan^2\frac{x}{2}}{1-\tan\frac{x}{x}}f(\sin x)=-\frac{2\tan\frac{x}{2}}{1-\tan\frac{x}{2}}$$

គេទាញ $f(\sin x)=\dfrac{2\tan\frac{x}{2}}{1+\tan^2\frac{x}{2}}=\dfrac{2t}{1+t^2}=\sin x$

ដូចនេះ $f(x)=x$ ។

លំហាត់ទី៩

គេឱ្យអនុគមន៍ $f(t)=(t)^{\ln^2 t+3\ln t+3}$ ដែល $t>0$ និង $t\neq 1$ ។

គេពិនិត្យស្វ៊ីតនៃចំនួនពិត (u_n) កំណត់ដោយ $u_1=f(e)$ និងចំពោះគ្រប់

ចំនួនគត់វិជ្ជមាន n គេមាន $u_{n+1}=f(u_n)$ ។

ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ចូរស្រាយថា $1+\ln u_{n+1}=(1+\ln u_n)^3$

រួចទាញរកតួ u_n ជាអនុគមន៍នៃ n ។

ដំណោះស្រាយ

ស្រាយថា $1+\ln u_{n+1}=(1+\ln u_n)^3$

គេមាន $f(t)=(t)^{\ln^2 t+3\ln t+3}$

គេបាន $u_{n+1}=f(u_n)=(u_n)^{\ln^2 u_n+3\ln u_n+3}$

នាំឱ្យ $\ln u_{n+1}=\ln(u_n)^{\ln^2 u_n+3\ln u_n+3}$

$$\ln u_{n+1}=(\ln^2 u_n+3\ln u_n+3)\ln u_n$$

$$\ln u_{n+1}=\ln^3 u_n+3\ln^2 u_n+3\ln u_n$$

$$\ln u_{n+1}=(1+\ln u_n)^3-1$$

ដូចនេះ $1+\ln u_{n+1}=(1+\ln u_n)^3$ ។

ទាញរកតួ u_n ជាអនុគមន៍នៃ n :

គេមាន $1+\ln u_{n+1}=(1+\ln u_n)^3$

គេបាន $\ln(1+\ln u_{n+1}) = \ln(1+\ln u_n)^3$

ឬ $\ln(1+\ln u_{n+1}) = 3\ln(1+\ln u_n)$

តាងស្វ៊ីតជំនួយ $v_n = \ln(1+\ln u_n)$

គេបាន $v_{n+1} = \ln(1+\ln u_{n+1})$

$v_{n+1} = 3\ln(1+\ln u_n)$

$v_{n+1} = 3\,v_n$

ទំនាក់ទំនងនេះបញ្ជាក់ថា (v_n) ជាស្វ៊ីតធរណីមាត្រមានរេសុង $q = 3$

និងតួ $v_1 = \ln(1+\ln u_1)$ តែ $u_1 = f(e) = e^{\ln^2 e+3\ln e+3} = e^7$

នោះ $v_1 = \ln(1+\ln e^7) = \ln 8 = 3\ln 2$ ។

តាមរូបមន្តគេបាន $v_n = v_1 \times q^{n-1} = 3\ln 2\times 3^{n-1} = 3^n \ln 2$

ដោយ $v_n = \ln(1+\ln u_n)$ នោះគេទាញបាន :

$\ln(1+\ln u_n) = 3^n \ln 2$ ឬ $1+\ln u_n = 2^{3^n}$

គេទាញ $u_n = e^{2^{3^n}-1}$ ដែល $e = 2.7182...$ ។

ដូចនេះតួទី n នៃស្វ៊ីតគឺ $u_n = e^{2^{3^n}-1}$ ។

លំហាត់ទី៦

កំណត់គ្រប់ចំនួនគត់វិជ្ជមាន $\mathbf{a}$, $\mathbf{b}$, $\mathbf{c}$ ដើម្បីឱ្យបណ្តាសមីការខាងក្រោម

$$\begin{cases} x^2 - 2ax + b = 0 \\ x^2 - 2bx + c = 0 \\ x^2 - 2cx + a = 0 \end{cases}$$ មានឫសជាចំនួនគត់វិជ្ជមាន ។

ដំណោះស្រាយ

កំណត់គ្រប់ចំនួនគត់វិជ្ជមាន $\mathbf{a}$, $\mathbf{b}$, $\mathbf{c}$

ដើម្បីឱ្យសមីការទាំងអស់មានឫសជាចំនួនគត់វិជ្ជមានលុះត្រាតែឌីសគ្រីមីណង់

ទាំងអស់ $a^2 - b$, $b^2 - c$, $c^2 - a$ សុទ្ធតែជាការេប្រាកដ ។

គ្រប់ចំនួនគត់វិជ្ជមាន a , b , c គេមាន $a^2 - b \ge (a-1)^2$

គេទាញ $b \ge 2a - 1$ ។ ដូចគ្នាដែរគេទាញ $c \ge 2b - 1$ និង $a \ge 2c - 1$

គេបាន $\begin{cases} b \ge 2a - 1 \\ c \ge 2b - 1 \\ a \ge 2c - 1 \end{cases} \Leftrightarrow \begin{cases} 4b \ge 8a - 4 & (1) \\ 2c \ge 4b - 2 & (2) \\ a \ge 2c - 1 & (3) \end{cases}$

បូកវិសមភាព $(1),(2),(3)$ គេបាន $a \ge 8a - 7$ នាំឱ្យ $a \le 1$

ដោយ a ជាចំនួនគត់វិជ្ជមាននោះ $a = 1$ ហើយដូចគ្នាដែរ $b = 1$, $c = 1$ ។

ដូចនេះ $(a, b, c) = (1, 1, 1)$ ជាចម្លើយតែមួយគត់ ។

លំហាត់ទី៧

គេឱ្យ M ជាទីប្រជុំទម្ងន់នៃត្រីកោណ ABC ។

បើបន្ទាត់ AB ប៉ះទៅនឹងរង្វង់ចារឹកក្រៅនៃត្រីកោណ AMC នោះបង្ហាញថា

$$\sin\angle CMA + \sin\angle \sin CBM \le \frac{2}{\sqrt{3}}$$ ។

ដំណោះស្រាយ

ស្រាយថា



យក G ជាចំណុចកណ្ដាលនៃជ្រុង [AB] ។

តាង a,b,c ជាប្រវែងជ្រុង BC , CA , AB ហើយ m_a, m_b, m_c

ជារង្វាស់មេដ្យានគូសពីកំពូល A,B,C រៀងគ្នា ។

ដោយ A ជាចំនុចប៉ះរវាងបន្ទាត់ (AB) ជាមួយរង្វង់ផ្ចិត M' នោះគេមាន

$GA^2 = GM.GC = \frac{1}{3}GC^2$ (ព្រោះ $GM = \frac{1}{3}GC$)

ដោយ $GA = \frac{AB}{2} = \frac{c}{2}$, $GC = m_c$ គេបាន $\frac{c^2}{4} = \frac{1}{3}{m_c}^2$

តាមទ្រឹស្តីបទមេដ្យានគេមាន ${m_c}^2 = \frac{a^2+b^2}{2} - \frac{c^2}{4}$

គេទាញ $\frac{c^2}{4} = \frac{1}{3}(\frac{a^2+b^2}{2} - \frac{c^2}{4})$ ឬ $a^2 + b^2 = 2c^2$ ។

ហេតុនេះ ${m_c}^2 = \frac{2c^2}{2} - \frac{c^2}{4} = \frac{3c^2}{4}$ ឬ $m_c = \frac{\sqrt{3}}{2}c$

ហើយ ${m_a}^2 = \frac{b^2+c^2}{2} - \frac{a^2}{4} = \frac{2b^2+2c^2-a^2}{4} = \frac{3b^2}{4}$

នាំឱ្យ $m_a = \frac{\sqrt{3}}{2}b$ ហើយ $m_b = \frac{\sqrt{3}}{2}a$ ។

តាង S ជាក្រឡាផ្ទៃនៃត្រីកោណ ABC ហើយ AA' , BB' ជាមេដ្យាន

គេបាន $S_{CAM} = \frac{1}{2}AM.AC\sin\angle CAM = \frac{1}{4}AA'.AC\sin\angle CAM$

ឬ $S_{CAM} = \frac{1}{4}m_a b\sin\angle CAM = \frac{1}{2}S_{AA'C} = \frac{1}{4}S$

គេទាញបាន $\sin\angle CAM = \frac{S}{m_a b}$ ហើយ $\sin\angle CBM = \frac{S}{m_b a}$

គេបាន $\sin\angle CAM + \sin\angle CBM = \frac{S}{m_a b} + \frac{S}{m_b a}$

តែ $S=\frac{1}{2}ab\sin C$ ហើយ $m_a=\frac{\sqrt{3}}{2}b$ និង $m_b=\frac{\sqrt{3}}{2}a$

គេបាន $\sin\angle CAM+\sin\angle CBM=\frac{a^2+b^2}{\sqrt{3}ab}\sin C \quad (1)$

តាមទ្រឹស្តីបទកូស៊ីនួស $c^2=a^2+b^2-2ab\cos C$

គេទាញ $\frac{a^2+b^2}{2}=a^2+b^2-2ab\cos C$ ព្រោះ $a^2+b^2=2c^2$

ហេតុនេះ $a^2+b^2=4bc\cos C \quad (2)$

យកទំនាក់ទំនង (2) ជំនួសក្នុង (1) គេបាន ៖

$$\sin\angle CAM+\sin\angle CBM=\frac{4\sin C\cos C}{\sqrt{3}}=\frac{2}{\sqrt{3}}\sin 2C\le\frac{2}{\sqrt{3}}$$

ដូចនេះ $\sin\angle CAM+\sin\angle CBM\le\frac{2}{\sqrt{3}}$ ។

លំហាត់ទី៨

គេឱ្យត្រីកោណ ABC មានជ្រុង a , b , c និងមានមុំក្នុង α , β , γ ។

បើ $\alpha = 3\beta$ ចូរបង្ហាញថា $(a-b)(a^2-b^2) = bc^2$?

ដំណោះស្រាយ

ស្រាយថា $(a-b)(a^2-b^2) = bc^2$

តាមទ្រឹស្តីបទស៊ីនូស $a = 2R\sin\alpha$, $b = 2R\sin\beta$, $c = 2R\sin\gamma$

គេបាន $(a-b)(a^2-b^2) = (a-b)^2(a+b)$

ដោយ $a-b = 2R(\sin\alpha - \sin\beta)$

$$= 2R(\sin 3\beta - \sin\beta)$$

$$= 4R\sin\beta\cos 2\beta$$

ហើយ $a+b = 2R(\sin\alpha + \sin\beta)$

$$= 2R(\sin 3\beta + \sin\beta)$$

$$= 4R\sin 2\beta\cos\beta$$

$$= 8R\sin\beta\cos^2\beta$$

គេបាន $(a-b)(a^2-b^2) = 16R^2\sin^2\beta\cos^2 2\beta . 8R\sin\beta\cos^2\beta$

$$= 8R^3\sin^2 4\beta\sin\beta$$

$$= 8R^3\sin^2(\pi - 4\beta)\sin\beta$$

$$= 8R^3\sin^2\gamma\sin\beta$$

ដូចនេះ $(a-b)(a^2-b^2) = bc^2$ ។

លំហាត់ទី៩

គេឱ្យត្រីកោណ ABC មួយមានជ្រុង a , b , c ។

D , E, F ជាជើងកម្ពស់គូសចេញពីកំពូល A , B , C រៀងគ្នា ។

តាង $AD = h_a$, $BE = h_b$, $CF = h_c$ ជារង្វាស់កម្ពស់នៃត្រីកោណ

និង $HA = q_A$, $HB = q_B$, $HC = q_c$ ដែល H ជាអរតូសង់ត្រីកោណ។

ចូរស្រាយថា $h_a q_a + h_b q_b + h_c q_c = \frac{a^2+b^2+c^2}{2}$ ។

ដំណោះស្រាយ

ស្រាយថា $h_a q_a + h_b q_b + h_c q_c = \frac{a^2+b^2+c^2}{2}$



យើងមាន ΔACD ដូចត្រីកោណ ΔAHE

គេបាន $AD.AH = AC.AE$ ឬ $h_a q_a = b.AE$ (1)

ដូចគ្នាដែរ ΔABD ដូចត្រីកោណ ΔAHF

គេបាន $AD.AH = AB.AF$ ឬ $h_a q_a = c.AF$ (2)

បូកសមភាព (1) និង (2) អង្គ និង អង្គគេបាន :

$2h_a q_a = b.AE + c.AF$ ឬ $h_a q_a = \dfrac{b.AE + c.AF}{2}$

ដូចគ្នាដែរ $h_b q_b = \dfrac{c.BF + a.BD}{2}$ និង $h_c q_c = \dfrac{a.CD + b.CE}{2}$

គេបាន $h_a q_a + h_b q_b + h_c q_c = \dfrac{a(CD + BD) + b(AE + CE) + c(AF + BF)}{2}$

ដោយ $CD + BD = a$, $AE + CE = b$, $AF + BF = c$

ដូចនេះ $h_a q_a + h_b q_b + h_c q_c = \dfrac{a^2 + b^2 + c^2}{2}$ ។

លំហាត់ទី១០

ចូរកំណត់គ្រប់ចំនួនគត់វិជ្ជមាន x , y , z បើគេដឹងថា

$$\frac{13}{x^2}+\frac{1996}{y^2}=\frac{z}{1997}$$ ។

ដំណោះស្រាយ

កំណត់គ្រប់ចំនួនគត់វិជ្ជមាន x , y , z :

គេមាន $\frac{13}{x^2}+\frac{1996}{y^2}=\frac{z}{1997}$ (*)

តាង d ជាតួចែករួមធំបំផុតនៃ x និង y នោះ $x=md$ និង $y=nd$

ដែល m និង n ជាចំនួនគត់វិជ្ជមានបឋមរវាងគ្នា ។

តាមសមីការ (*) គេអាចសរសេរ $\frac{13}{m^2d^2}+\frac{1996}{n^2d^2}=\frac{z}{1997}$

ឬ $13\times1997n^2+1996\times1997m^2=m^2n^2d^2z$

ដោយ m និង n ជាចំនួនគត់វិជ្ជមានបឋមរវាងគ្នានោះយើងត្រូវមាន :

13×1997 ចែកដាច់នឹង m^2 និង 1996×1997 ចែកដាច់នឹងn^2 ។

ដោយគេមាន $1966=2^2\times449$ ហើយ 13 , 449 , 1997 ជាចំនួនបឋម

ដូចនេះតម្លៃ m និង n បំពេញលក្ខខណ្ឌខាងលើនេះគឺ $m=1$, $n=1$

ឬ $m=1$, $n=2$ ។

-ករណី $m=1$, $n=1$

គេបាន $d^2z=(13+1996).1997=7^2.41.1997$

ដោយ 1997 បឋមជាមួយ 41 និង 7 នោះគេទាញបាន $d=1$ ឬ $d=7$

ដូចនេះគេបានចម្លើយ $x=1$, $y=1$, $z=4011973$

ឬ $x=7$, $y=7$, $z=81877$ ។

-ករណី $m=1$, $n=2$

គេបាន $d^2z=(13+449).1997=2^9.1997$

គេទាញបាន $d=1$, 2 , 4 , 8 , 16 ។ ដូចនេះគេទាញបានចម្លើយ :

$(x,y,z)=(1\ ,\ 2\ ,\ 1022464);(2,4,255616);(4,8,63904)$

$(8,16,16976);(16,32,3994)$

លំហាត់ទី១១

គេឱ្យ a,b,c ជាចំនួនពិតវិជ្ជមាន ។

ចូរបង្ហាញថា :

$$\frac{a^2b(b-c)}{a+b}+\frac{b^2c(c-a)}{b+c}+\frac{c^2a(a-b)}{c+a}\geq 0$$

(BMO 2010)

ដំណោះស្រាយ

បង្ហាញថា :

$$\frac{a^2b(b-c)}{a+b}+\frac{b^2c(c-a)}{b+c}+\frac{c^2a(a-b)}{c+a}\geq 0$$

គេមាន

$$\frac{a^2b(b-c)}{a+b}=\frac{a^2b^2-a^2bc}{a+b}=\frac{(a^2b^2+ab^2c)-(a^2bc+ab^2c)}{a+b}$$

$$=\frac{ab^2(a+c)-abc(a+b)}{a+b}=ab^2.\frac{a+c}{a+b}-abc$$

គេបាន $\frac{a^2b(b-c)}{a+b}=ab^2.\frac{a+c}{a+b}-abc \quad (1)$

ស្រាយបំភ្លឺដូចគ្នាដែរគេបាន $\frac{b^2c(c-a)}{b+c}=bc^2\frac{b+a}{b+c}-abc \quad (2)$

និង $\frac{c^2a(a-b)}{c+a}=ca^2\frac{c+b}{c+a} \quad (3)$

បូកសមភាព $(1),(2)$ និង (3) អង្គនិងអង្គគេបាន :

$$T = ab^2\frac{c+b}{a+b} + bc^2\frac{b+a}{b+c} + ca^2\frac{c+b}{c+a} - 3abc$$

ដែល $T = \frac{a^2b(b-c)}{a+b} + \frac{b^2c(c-a)}{b+c} + \frac{c^2a(a-b)}{c+a}$

តាមវិសមភាព $AM - GM$ គេមាន :

$$ab^2\frac{c+b}{a+b} + bc^2\frac{b+a}{b+c} + ca^2\frac{c+b}{c+a} \geq 3abc$$

ឬ $ab^2\frac{c+b}{a+b} + bc^2\frac{b+a}{b+c} + ca^2\frac{c+b}{c+a} - 3abc \geq 0$

ដូចនេះ $\frac{a^2b(b-c)}{a+b} + \frac{b^2c(c-a)}{b+c} + \frac{c^2a(a-b)}{c+a} \geq 0$ ។

លំហាត់ទី១២

គេឱ្យ $a, b, c > 0$ ដែល $abc \geq 1$ ។

ចូរបង្ហាញថា $(1+\frac{a^2}{1+a})(1+\frac{b^2}{1+b})(1+\frac{c^2}{1+c}) \geq \frac{27}{8}$?

ដំណោះស្រាយ

ស្រាយថា $(1+\frac{a^2}{1+a})(1+\frac{b^2}{1+b})(1+\frac{c^2}{1+c}) \geq \frac{27}{8}$

គេមាន $a^2+1 \geq 2a$ គ្រប់ $a > 0$

គេបាន $4a^2+4a+4 \geq 3a^2+6a+3 = 3(a+1)^2$

គេទាញ $a^2+a+1 \geq \frac{3(a+1)^2}{4}$

ឬ $\frac{a^2+a+1}{a+1} \geq \frac{3(a+1)}{4}$

ឬ $1+\frac{a^2}{1+a} \geq \frac{3\sqrt{a}}{2}$ ព្រោះ $a+1 \geq 2\sqrt{a}$

ដូចគ្នាដែរ $1+\frac{b^2}{1+b} \geq \frac{3\sqrt{b}}{2}$ និង $1+\frac{c^2}{1+c} \geq \frac{3\sqrt{c}}{2}$

គេបាន$(1+\frac{a^2}{1+a})(1+\frac{b^2}{1+b})(1+\frac{c^2}{1+c}) \geq \frac{27\sqrt{abc}}{8}$

ដោយសម្មតិកម្ម $abc \geq 1$ នោះ $\frac{27\sqrt{abc}}{8} \geq \frac{27}{8}$

ដូចនេះ $(1+\frac{a^2}{1+a})(1+\frac{b^2}{1+b})(1+\frac{c^2}{1+c}) \geq \frac{27}{8}$ ។

លំហាត់ទី១៣

គេឱ្យត្រីកោណសមង្ស័ ABC មួយមាន G ជាទីប្រជុំទម្ងន់ ។

D ជាចំនុចមួយនៃ [AB] ដែល $AD = AG$ ។

បន្ទាត់ DG កាត់ AC និង BC ត្រង់ E និង F រៀងគ្នា ។

ចូរបង្ហាញថា $ED = EF$

ដំណោះស្រាយ

ស្រាយថា $ED = EF$



ដោយ $AD = AG$ នោះ $\angle ADG = \angle AGD = \dfrac{180^o - 30^o}{2} = 75^o$

ហើយ $\angle AGE = 180^o - 75^o = 105^o$ និង $\angle CGE = 120^o - 105^o = 15^o$ ។

ម្យ៉ាងទៀត $\angle GCF = 150^o$ នោះ $\angle CFG = 15^o$ ។

គេទាញបាន $CF = CG = AG = AD$ ។

តាមទ្រឹស្តីបទស៊ីនូសអនុវត្តន៍ក្នុងត្រីកោណ ADE គេបាន :

$$\frac{DE}{\sin 60^o} = \frac{AD}{\sin \angle AED} \quad (1)$$

តាមទ្រឹស្តីបទស៊ីនូសអនុវត្តន៍ក្នុងត្រីកោណ CEF គេបាន :

$$\frac{CF}{\sin \angle CEF} = \frac{EF}{\sin 120^o}$$

ដោយ $CF = AD$ និង $\angle AED = \angle CEF$ (មុំទល់កំពូល)

គេបាន $\frac{AD}{\sin \angle AED} = \frac{EF}{\sin 120^o} \quad (2)$

តាម (1) និង (2) គេទាញបាន $\frac{DE}{\sin 60^o} = \frac{EF}{\sin 120^o}$

ដោយ $\sin 120^o = \sin(180^o - 60^o) = \sin 60^o$

ដូចនេះ $DE = EF$ ។

លំហាត់ទី១៤

គេឱ្យ a, b, c ជាបីចំនួនពិតវិជ្ជមាន ។ ចូរបង្ហាញថា :

$$\frac{a^5+b^5+c^5-(a+b+c)^5}{a^3+b^3+c^3-(a+b+c)^3} \geq \frac{10}{9}(a+b+c)^2$$

ដំណោះស្រាយ

គេមានសមភាព :

$$a^3+b^3+c^3=(a+b+c)^3-3(a+b)(b+c)(c+a)$$

$$a^5+b^5+c^5=(a+b+c)^5-5(a+b)(b+c)(c+a)(a^2+b^2+c^2+ab+bc+ca)$$

គេបាន :

$$\frac{a^5+b^5+c^5-(a+b+c)^5}{a^3+b^3+c^3-(a+b+c)^3}=\frac{5}{3}(a^2+b^2+c^2+ab+bc+ca)$$

យើងនឹងស្រាយថា $\frac{5}{3}(a^2+b^2+c^2+ab+bc+ca) \geq \frac{10}{9}(a+b+c)^2$

ឬ $3(a^2+b^2+c^2+ab+bc+ca) \geq 2(a+b+c)^2$

ឬ $$a^2+b^2+c^2 \geq ab+bc+ca$$

តាមវិសមភាព $AM-GM$ គេមាន :

$$ab+bc+ca \leq \frac{a^2+b^2}{2}+\frac{b^2+c^2}{2}+\frac{c^2+a^2}{2}=a^2+b^2+c^2 \quad \text{ពិត}$$

ដូចនេះ $\frac{a^5+b^5+c^5-(a+b+c)^5}{a^3+b^3+c^3-(a+b+c)^3} \geq \frac{10}{9}(a+b+c)^2$ ។

លំហាត់ទី១៩

គេឱ្យស្វ៊ីតចំនួនពិត (a_n) កំណត់ដោយ :

$a_0 = 4$, $a_1 = 9$ និង $a_{n+2} = 6a_{n+1} - 8a_n + 3$ ដែល $n = 0 , 1 , 2 , ...$

ចូរស្រាយថា a_n ជាការេប្រាកដចំពោះគ្រប់ $n \geq 0$ ។

ដំណោះស្រាយ

ស្រាយថា a_n ជាការេប្រាកដ

គេមាន $a_{n+2} = 6a_{n+1} - 8a_n + 3 \quad (1)$

តាងស្វ៊ីតចំនួនពិត $b_n = a_n + k$ ដែល k ជាចំនួនពិតថេរ ។

គេទាញ $a_n = b_n - k$, $a_{n+1} = b_{n+1} - k$, $a_{n+2} = b_{n+2} - k$

ទំនាក់ទំនង (1) អាចសរសេរ :

$$b_{n+2} - k = 6(b_{n+1} - k) - 8(b_n - k) + 3$$

$$b_{n+2} = 6b_{n+1} - 8b_n + 3k + 3 \qquad (2)$$

បើ $3k + 3 = 0 \Rightarrow k = -1$ នោះទំនាក់ទំនង (2) ក្លាយទៅជា :

$b_{n+2} = 6b_{n+1} - 8b_n$ មានសមីការសម្គាល់ $x^2 - 6x + 8 = 0$

មានឬស $x_1 = 2$, $x_2 = 4$ ។

តាងស្វ៊ីតជំនួយ $\begin{cases} x_n = b_{n+1} - 2b_n \\ y_n = b_{n+1} - 4b_n \end{cases}$

គេបាន $\begin{cases} x_{n+1} = b_{n+2} - 2b_{n+1} \\ y_{n+1} = b_{n+2} - 4b_{n+1} \end{cases}$ ដោយ $b_{n+2} = 6b_{n+1} - 8b_n$

នោះ $\begin{cases} x_{n+1} = 4(b_{n+1} - 2b_n) \\ y_{n+1} = 2(b_{n+1} - 4b_n) \end{cases}$ ឬ $\begin{cases} x_{n+1} = 4x_n \\ y_{n+1} = 2y_n \end{cases}$

គេទាញបាន (x_n) និង (y_n) ជាស្វ៊ីតធរណីមាត្រមានរេសុង រៀងគ្នា

$q_1 = 4$, $q_2 = 2$ ។

តាមរូបមន្ត $x_n = x_0.q_1{}^n$ និង $y_n = y_0.q_2{}^n$

ដោយ $x_0 = b_1 - 2b_0 = (a_1 + k) - 2(a_0 + k) = 2$

និង $y_0 = b_1 - 4b_0 = (a_1 + k) - 4(a_0 + k) = -4$

គេបាន $x_n = 2.4^n$ និង $y_n = -4.2^n$ ។

ដោយ $\begin{cases} x_n = b_{n+1} - 2b_n \\ y_n = b_{n+1} - 4b_n \end{cases}$ នោះ $\begin{cases} b_{n+1} - 2b_n = 2.4^n \\ b_{n+1} - 4b_n = -4.2^n \end{cases}$

ធ្វើផលសងគេបាន $2b_n = 2.4^n + 4.2^n \Rightarrow b_n = 4^n + 2.2^n$

ដោយ $a_n = b_n - k = 4^n + 2.2^n + 1$ (ព្រោះ $k = -1$)

ដូចនេះ $a_n = (2^n + 1)^2$ ជាការេប្រាកដគ្រប់ $n \in IN$ ។

លំហាត់ទី១៦

គេឱ្យត្រីកោណ ABC មួយ ។ ចូរកំណត់តម្លៃអប្បបរមានៃ :

$$T=\frac{\cos^2\frac{A}{2}\cos^2\frac{B}{2}}{\cos^2\frac{C}{2}}+\frac{\cos^2\frac{B}{2}\cos^2\frac{C}{2}}{\cos^2\frac{A}{2}}+\frac{\cos^2\frac{C}{2}\cos^2\frac{A}{2}}{\cos^2\frac{B}{2}}$$

(Vietnam Team Selection Tests 2007)

ដំណោះស្រាយ

កំណត់តម្លៃអប្បបរមានៃ T

$$T=\frac{\cos^2\frac{A}{2}\cos^2\frac{B}{2}}{\cos^2\frac{C}{2}}+\frac{\cos^2\frac{B}{2}\cos^2\frac{C}{2}}{\cos^2\frac{A}{2}}+\frac{\cos^2\frac{C}{2}\cos^2\frac{A}{2}}{\cos^2\frac{B}{2}}$$

គេមាន $\cos\frac{A}{2}=\sqrt{\frac{p(p-a)}{bc}}\ ,\ \cos\frac{B}{2}=\sqrt{\frac{p(p-b)}{ca}}\ ,\ \cos\frac{C}{2}=\sqrt{\frac{p(p-c)}{ab}}$

គេបាន $T=\frac{p(p-a)(p-b)}{c^2(p-c)}+\frac{p(p-b)(p-c)}{a^2(p-a)}+\frac{p(p-a)(p-c)}{b^2(p-b)}$

តាមរូបមន្តហេរ៉ុង $S=\sqrt{p(p-a)(p-b)(p-c)}$

គេបាន $T=S^2\left[\frac{1}{c^2(p-c)^2}+\frac{1}{a^2(p-a)^2}+\frac{1}{b^2(p-b)^2}\right]$

លំហាត់ទី១៧

គណនាផលបូក $S_n = \frac{1^3}{2} + \frac{2^3}{2^2} + \frac{3^3}{2^3} + ... + \frac{n^3}{2^n}$

រួចទាញរកលីមីតនៃ S_n កាលណា $n \to +\infty$ ។

ដំណោះស្រាយ

គណនាផលបូក

គេមាន $S_n = \frac{1^3}{2} + \frac{2^3}{2^2} + \frac{3^3}{2^3} + ... + \frac{n^3}{2^n} = \sum_{k=1}^{n}\left(\frac{k^3}{2^k}\right)$

តាងអនុគមន៍ $f(k) = ak^3 + bk^2 + ck + d$ ដែលផ្ទៀងផ្ទាត់សមីការ :

$\frac{k^3}{2^k} = \frac{f(k)}{2^k} - \frac{f(k+1)}{2^{k+1}}$ ឬ $2k^3 = 2f(k) - f(k+1)$

$$2k^3 = 2(ak^3 + bk^2 + ck + d) - [a(k+1)^3 + b(k+1)^2 + c(k+1) + d]$$

$$2k^3 = ak^3 + (b-3a)k^2 + (c-3a-2b)k + d - a - b - c$$

គេទាញ $\begin{cases} a = 2 \\ b - 3a = 0 \\ c - 3a - 2b = 0 \\ d - a - b - c = 0 \end{cases}$ នាំឱ្យ $a = 2, b = 6, c = 18, d = 26$

ហេតុនេះ $f(k) = 2k^3 + 6k^2 + 18k + 26$

គេបាន $S_n = \sum_{k=1}^{n}\left[\frac{f(k)}{2^k} - \frac{f(k+1)}{2^{k+1}}\right] = \frac{f(1)}{2} - \frac{f(n+1)}{2^{n+1}}$

ដោយ $f(k) = 2k^3 + 6k^2 + 18k + 26$

គេបាន $f(1) = 2 + 6 + 18 + 26 = 52$

ហើយ $f(n+1) = 2(n+1)^3 + 6(n+1)^2 + 18(n+1) + 26$

$$= 2n^3 + 12n^2 + 36n + 50$$

គេបាន $S_n = \frac{52}{2} - \frac{2n^3 + 12n^2 + 36n + 52}{2^{n+1}}$

ដូចនេះ $S_n = 26 - \frac{n^3 + 6n^2 + 18n + 26}{2^n}$ និង $\lim_{n\to+\infty} S_n = 26$ ។

លំហាត់ទី១៨

គេឱ្យអនុគមន៍ f កំណត់ដោយ $f(n+1)-2f(n)=\dfrac{n.2^{n+1}}{(n+1)!}$ គ្រប់ $n\in IN$

និង $f(o)=1$ ។ គណនាលីមីត $\lim\limits_{n\to+\infty}[\dfrac{f(n)}{2^n}]$?

ដំណោះស្រាយ

គណនាលីមីត $\lim\limits_{n\to+\infty}[\dfrac{f(n)}{2^n}]$

គេមាន $f(n+1)-2f(n)=\dfrac{n.2^{n+1}}{(n+1)!}$

ចែកអង្គទាំងពីរនឹង 2^{n+1} គេបាន :

$$\frac{f(n+1)}{2^{n+1}}-\frac{f(n)}{2^n}=\frac{n}{(n+1)!}$$

ដោយ $\dfrac{n}{(n+1!}=\dfrac{(n+1)-1}{(n+1)!}=\dfrac{1}{n!}-\dfrac{1}{(n+1)!}$

គេបាន $\sum\limits_{k=0}^{n-1}\left[\dfrac{f(k+1)}{2^{k+1}}-\dfrac{f(k)}{2^k}\right]=\sum\limits_{k=0}^{n-1}\left[\dfrac{1}{k!}-\dfrac{1}{(k+1)!}\right]$

$$\frac{f(n)}{2^n}-1=1-\frac{1}{n!} \text{ ឬ } \frac{f(n)}{2^n}=2-\frac{1}{n!}$$

គេបាន $\lim\limits_{n\to+\infty}\left[\dfrac{f(n)}{2^n}\right]=\lim\limits_{n\to+\infty}\left(2-\dfrac{1}{n!}\right)=2$ ព្រោះ $\lim\limits_{n\to+\infty}\left(\dfrac{1}{n!}\right)=0$ ។

ដូចនេះ $\lim\limits_{n\to+\infty}[\dfrac{f(n)}{2^n}]=2$ ។

លំហាត់ទី១៩

ចំពោះគ្រប់ចំនួនពិត $x \in (0, \frac{\pi}{4})$

ចូរបង្ហាញថា $(\cos x)^{\cos x} > (\sin x)^{\sin x}$

ដំណោះស្រាយ

បង្ហាញថា $(\cos x)^{\cos x} > (\sin x)^{\sin x}$

តាមវិសមភាព Bernoulli ចំពោះគ្រប់ចំនួន x និង a ដែល $x > -1$ និង $a > 1$

យើងមាន $(1+x)^a \geq 1 + ax$ ។

ហេតុនេះចំពោះ $0 < x < \frac{\pi}{4}$ គេបាន :

$$(\cos^2 x)^{\frac{\cos x}{\sin x}} = (1-\sin x)^{\frac{\cos x}{\sin x}}.(1+\sin x)^{\frac{\cos x}{\sin x}}$$

ដោយ $(1-\sin x)^{\frac{\cos x}{\sin x}} > 1 - \cos x$ និង $(1+\sin x)^{\frac{\cos x}{\sin x}} > 1 + \cos x$

គេបាន $(\cos^2 x)^{\frac{\cos x}{\sin x}} > (1-\cos x)(1+\cos x) = \sin^2 x$

គេទាញ $(\cos x)^{\frac{\cos x}{\sin x}} > \sin x$

$$\ln(\cos x)^{\frac{\cos x}{\sin x}} > \ln(\sin x)$$

$$\frac{\cos x}{\sin x}\ln(\cos x) > \ln(\sin x)$$

$$\cos x \ln(\cos x) > \sin x \ln(\sin x)$$

$$\ln(\cos x)^{\cos x} > \ln(\sin x)^{\sin x}$$

ដូចនេះ $(\cos x)^{\cos x} > (\sin x)^{\sin x}$ ។

លំហាត់ទី២០

គេឱ្យ D និង E ជាចំណុចនៅលើជ្រុង AB និង CA នៃត្រីកោណ ABC ដោយដឹងថា DE ស្របទៅនឹង BC ហើយ DE ប៉ះទៅនឹងរង្វង់ចារឹកក្នុងត្រីកោណ ABC ។ ចូរបង្ហាញថា $DE \le \frac{AB+BC+CA}{8}$

(Italy 1999)

ដំណោះស្រាយ



បង្ហាញថា $DE \le \frac{AB+BC+CA}{8}$

តាង a , b , c ជាជ្រុងនៃ ΔABC

នឹង $p = \frac{a+b+c}{2}$ ជាកន្លះបរិមាត្រ ។

គេមាន $BC \,//\, DE$ តាមទ្រឹស្តីបទតាឡែស

គេបាន $\frac{DE}{BC} = \frac{AD}{AB} = \frac{AE}{AC}$

ឬ $\frac{DE}{BC} = \frac{DE+AD+AE}{BC+AB+AC}$ ដោយ $\begin{cases} AD = AP - PD = AP - DM \\ AE = AQ - EQ = AP - ME \end{cases}$

គេបាន $\frac{DE}{BC} = \frac{DE+2AP-(DM+ME)}{BC+AB+AC} = \frac{2AP}{BC+AB+AC}$

ដោយ $AP = p - a$, $BC + AB + AC = a + b + c$

គេទាញ $\frac{DE}{a} = \frac{2(p-a)}{a+b+c}$ នាំឱ្យ $DE = \frac{2a(p-a)}{a+b+c} \le \frac{a+b+c}{8}$ ពិត

លំហាត់ទី២១

គេឱ្យ a , b , c , d ជាបីចំនួនពិតដែលផ្ទៀងផ្ទាត់វិសមភាព :

$(a^2+b^2-1)(c^2+d^2-1)>(ac+bd-1)^2$

ចូរបង្ហាញថា $a^2+b^2>1$ និង $c^2+d^2>1$ ។

ដំណោះស្រាយ

បង្ហាញថា $a^2+b^2>1$ និង $c^2+d^2>1$

តាង $x=1-a^2-b^2$ និង $y=1-c^2-d^2$

យើងឧបមាថា $x\geq 0$ និង $y\geq 0$

វិសមភាព $(a^2+b^2-1)(c^2+d^2-1)>(ac+bd-1)^2$

សមមូល $xy>(ac+bd-1)^2$

ឬ $4xy>(2ac+2bd-2)^2$

ដោយ $x+y=2-a^2-b^2-c^2-d^2$

នោះ $2ac+2bd-2=-a^2-b^2-c^2-d^2+2ac+2bd-x-y$

$$=-[(a-c)^2+(b-d)^2+x+y]$$

គេទាញ $4xy>[(a-c)^2+(b-d)^2+(x+y)]^2\geq(x+y)^2$

ឬ $4xy>x^2+2xy+y^2$

ឬ $(x-y)^2<0$ មិនពិត ។ នាំឱ្យការឧបមាខាងលើផ្ទុយពីការពិត ។

ដូចនេះគេទាញ $x<0$ និង $y<0$ នាំឱ្យ $a^2+b^2>1$ និង $c^2+d^2>1$ ។

លំហាត់ទី២២

គេឱ្យ a , b , c ជាបីចំនួនពិតវិជ្ជមានដែល $\sqrt{ab}+\sqrt{bc}+\sqrt{ca}=1$ ។

ចូរកំនត់តម្លៃអប្បបរមានៃកន្សោម $E=\frac{a^2}{a+b}+\frac{b^2}{b+c}+\frac{c^2}{c+a}$ ។

ដំណោះស្រាយ

កំនត់តម្លៃអប្បបរមានៃកន្សោម E

គេមាន $\frac{a^2}{a+b}=\frac{a^2+ab-ab}{a+b}=a-\frac{ab}{a+b}$

តាមវិសមភាព $AM-GM$ គេមាន $a+b\geq 2\sqrt{ab}$

គេបាន $\frac{1}{a+b}\leq\frac{1}{2\sqrt{ab}}$ ឬ $-\frac{ab}{a+b}\geq-\frac{\sqrt{ab}}{2}$

គេទាញ $\frac{a^2}{a+b}=a-\frac{ab}{a+b}\geq a-\frac{\sqrt{ab}}{2}$ (1)

ដូចគ្នាដែរ $\frac{b^2}{b+c}\geq b-\frac{\sqrt{bc}}{2}$ (2) ; $\frac{c^2}{c+a}\geq c-\frac{\sqrt{ca}}{2}$ (3)

បូកវិសមភាព (1); (2) & (3) គេទទួលបាន :

$$E\geq a+b+c-\frac{\sqrt{ab}+\sqrt{bc}+\sqrt{ca}}{2}=a+b+c-\frac{1}{2}$$

តាមវិសមភាព $Cauchy-Schwarz$ គេមាន :

$$a+b+c\geq\sqrt{ab}+\sqrt{bc}+\sqrt{ca}=1$$

គេទាញ $E\geq 1-\frac{1}{2}=\frac{1}{2}$ ។ ដូចនេះតម្លៃអប្បបរមានៃ E គឺ $E_{min}=\frac{1}{2}$ ។

លំហាត់ទី២៣

ចូរគណនាផលបូក :

$$S_n = \frac{2}{3+1} + \frac{2^2}{3^2+1} + \dots\dots + \frac{2^{n+1}}{3^{2^n}+1}$$

ដំណោះស្រាយ

គណនាផលបូក :

គេមាន $S_n = \frac{2}{3+1} + \frac{2^2}{3^2+1} + \dots\dots + \frac{2^{n+1}}{3^{2^n}+1} = \sum_{k=0}^{n}\left(\frac{2^{k+1}}{3^{2^k}+1}\right)$

ចំពោះគ្រប់ $x \neq 1$ យើងមាន :

$$\frac{1}{x+1} = \frac{x-1}{x^2-1} = \frac{1}{2}\left(\frac{1}{x-1} - \frac{1}{x+1}\right) - \frac{1}{x^2-1}$$

គេទាញ $\frac{1}{x+1} = \frac{1}{x-1} - \frac{2}{x^2-1}$

យក $x = 3^{2^k}$ គេបាន $\frac{1}{3^{2^k}+1} = \frac{1}{3^{2^k}-1} - \frac{2}{3^{2^{k+1}}-1}$

គុណនឹង 2^{k+1} គេបាន $\frac{2^{k+1}}{3^{2^k}+1} = \frac{2^{k+1}}{3^{2^k}-1} - \frac{2^{k+2}}{3^{2^{k+1}}-1}$

គេបាន :

$$S_n = \left(\frac{2}{3-1} - \frac{2^2}{3^2-1}\right) + \left(\frac{2^2}{3^2-1} - \frac{2^3}{3^{2^2}-1}\right) + \dots + \left(\frac{2^{n+1}}{3^{2^n}-1} - \frac{2^{n+2}}{3^{2^{n+1}}-1}\right)$$

ដូចនេះ $S_n = 1 - \frac{2^{n+2}}{3^{2^{n+1}}-1}$ ។

លំហាត់ទី២៤

គេឱ្យ $A=\frac{1}{1.2}+\frac{1}{3.4}+\frac{1}{4.5}+....+\frac{1}{1997.1998}$

និង $B=\frac{1}{1000.1998}+\frac{1}{1001.1997}+\frac{1}{1002.1996}+....+\frac{1}{1998.1000}$

ចូរបង្ហាញថា $\frac{A}{B}$ ជាចំនួនគត់ ?

ដំណោះស្រាយ

បង្ហាញថា $\frac{A}{B}$ ជាចំនួនគត់ :

គេមាន $A=\frac{1}{1.2}+\frac{1}{3.4}+\frac{1}{4.5}+....+\frac{1}{1997.1998}$

$$=1-\frac{1}{2}+\frac{1}{3}-\frac{1}{4}+\frac{1}{5}-\frac{1}{6}+...+\frac{1}{1997}-\frac{1}{1998}$$

$$=(1+\frac{1}{2}+\frac{1}{3}+....+\frac{1}{1998})-2(\frac{1}{2}+\frac{1}{4}+\frac{1}{6}+....+\frac{1}{1998})$$

$$=(1+\frac{1}{2}+\frac{1}{3}+...+\frac{1}{1998})-(1+\frac{1}{2}+\frac{1}{3}+...+\frac{1}{999})$$

$$=\frac{1}{1000}+\frac{1}{1001}+\frac{1}{1002}+.....+\frac{1}{1998}$$

ដោយ $A=\frac{1}{1000}+\frac{1}{1001}+....+\frac{1}{1998}\ (1)$

និង $A=\frac{1}{1998}+\frac{1}{1997}+....+\frac{1}{1000}\ (2)$

បូកទំនាក់ទំនង $(1)\,\&\,(2)$ គេបាន :

$$2A=2998(\frac{1}{1000.1998}+\frac{1}{1001.1997}+...+\frac{1}{1998.1000})=2998B$$

គេទាញបាន $\frac{A}{B}=1499$ ជាចំនួនគត់ ។

លំហាត់ទី២៩

គេឱ្យ x និង y ជាចំនួនគត់ដោយដឹងថា $x^3 + y^3 + (x+y)^3 + 30xy = 2000$

ចូរបង្ហាញថា $x + y = 10$ ។

ដំណោះស្រាយ

បង្ហាញថា $x + y = 10$

គេមាន $x^3 + y^3 + (x+y)^3 + 30xy = 2000$

គេបាន $2(x+y)^3 - 3x^2y - 3xy^2 + 30xy - 2000 = 0$

$$2[(x+y)^3 - 1000] - 3xy(x+y-10) = 0$$

$$(x+y-10)[\ 2(x+y)^2 + 20(x+y) + 200 - 3xy\,] = 0$$

ដោយ $f(x,y) = 2(x+y)^2 + 20(x+y) + 200 - 3xy$

$$= 2x^2 + 2y^2 + xy + 20x + 20y + 200$$

$$= x^2 + xy + y^2 + (x^2 + 20x + 100) + (y^2 + 20y + 100)$$

$$= (x + \frac{y}{2})^2 + \frac{3y^2}{4} + (x+10)^2 + (y+10)^2 > 0$$

គេទាញបាន $x + y - 10 = 0$ ឬ $x + y = 10$

ដូចនេះ $x + y = 10$ ។

លំហាត់ទី២៦

គេឱ្យ $x_1, x_2, ..., x_n$ (ដែល $n \ge 2$) ជាចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់ :

$$\frac{1}{x_1+1998}+\frac{1}{x_2+1998}+....+\frac{1}{x_n+1998}=\frac{1}{1998}$$

ចូរបង្ហាញថា $\frac{\sqrt[n]{x_1.x_2...x_n}}{n-1} \ge 1998$ ។

ដំណោះស្រាយ

បង្ហាញថា $\frac{\sqrt[n]{x_1.x_2...x_n}}{n-1} \ge 1998$

គេមាន $\frac{1}{x_1+1998}+\frac{1}{x_2+1998}+....+\frac{1}{x_n+1998}=\frac{1}{1998}$

ឬ $\frac{1998}{x_1+1998}+\frac{1998}{x_2+1998}+....+\frac{1998}{x_n+1998}=1$

តាង $y_i=\frac{1998}{x_i+1}$ គេបាន $y_1+y_2+....+y_n=1$

គេទាញ $1-y_i=\sum_{j\neq i}(y_i)$ ដែល $1\le i\le n$ និង $1\le j\le n$

តាម $AM-GM$ គេមាន $\sum_{j\neq i}(y_i)\ge (n-1)\sqrt[n-1]{\prod_{j\neq i}(y_i)}$

គេបាន $1-y_i\ge (n-1)\sqrt[n-1]{\prod_{j\neq i}(y_i)}$

គេទាញ $\prod_{i=1}^{n}(1-y_i)\ge (n-1)^n\prod_{i=1}^{n}(y_i)$ ឬ $\prod_{i=1}^{n}(\frac{1-y_i}{y_i})\ge (n-1)^n$

តែ $\frac{1-y_i}{y_i}=\frac{x_i}{1998}$ នោះ $\frac{x_1x_2...x_n}{1998^n}\ge (n-1)^n$ ឬ $\frac{\sqrt[n]{x_1.x_2...x_n}}{n-1}\ge 1998$ ។

លំហាត់ទី២៧

គេឱ្យ x, y, z ជាបីចំនួនពិតវិជ្ជមានដែល $xyz = x + y + z$ ។

ចូរស្រាយថា $\frac{x+y}{1+z^2} + \frac{y+z}{1+x^2} + \frac{z+x}{1+y^2} \ge \frac{27}{2xyz}$ ។

ដំណោះស្រាយ

បង្ហាញថា $\frac{x+y}{1+z^2} + \frac{y+z}{1+x^2} + \frac{z+x}{1+y^2} \ge \frac{27}{2xyz}$

តាង $T = \frac{x+y}{1+z^2} + \frac{y+z}{1+x^2} + \frac{z+x}{1+y^2}$

ឬ $T = \frac{(x+y)^2}{x+y+z^2(x+y)} + \frac{(y+z)^2}{y+z+x^2(y+z)} + \frac{(z+x)^2}{z+x+y^2(z+x)}$

តាមវិសមភាព Cauchy – Schwarz គេមាន :

$$\frac{{a_1}^2}{b_1} + \frac{{a_2}^2}{b_2} + \frac{{a_3}^2}{b_3} + \dots + \frac{{a_n}^2}{b_n} \ge \frac{(a_1 + a_2 + a_3 + \dots + a_n)^2}{b_1 + b_2 + b_3 + \dots + b_n}$$

គេបាន :

$$T \ge \frac{\left[(x+y)+(y+z)+(z+x)\right]^2}{2(x+y+z)+z^2(x+y)+x^2(y+z)+y^2(z+x)}$$

$$T \ge \frac{4(x+y+z)^2}{2xyz+z^2x+z^2y+x^2y+x^2z+y^2z+y^2x}$$

$$T \ge \frac{4(x+y+z)^2}{(x+y)(y+z)(z+x)}$$

តាមវិសមភាព $AM-GM$ គេមាន :

$$(x+y)+(y+z)+(z+x)\geq 3\sqrt[3]{(x+y)(y+z)(z+x)}$$

$$2(x+y+z)\geq 3\sqrt[3]{(x+y)(y+z)(z+x)}$$

$$8(x+y+z)^3\geq 27(x+y)(y+z)(z+x)$$

គេទាញ $\dfrac{4(x+y+z)^2}{(x+y)(y+z)(z+x)}\geq\dfrac{27}{2(x+y+z)}=\dfrac{27}{2xyz}$

នាំឱ្យ $T\geq\dfrac{27}{2xyz}$

ដូចនេះ $\dfrac{x+y}{1+z^2}+\dfrac{y+z}{1+x^2}+\dfrac{z+x}{1+y^2}\geq\dfrac{27}{2xyz}$ ។

លំហាត់ទី២៨

ត្រីកោណមួយមានរង្វាស់ជ្រុងជាចំនួនគត់វិជ្ជមានហើយចារឹកក្រៅរង្វង់មួយមានរង្វាស់កាំស្មើ 1 ។ ចូរកំណត់ជ្រុងនៃត្រីកោណនេះ រួចបង្ហាញថាវាមានមុំមួយស្មើ 90^o ។

ដំណោះស្រាយ

កំណត់ជ្រុងនៃត្រីកោណ

តាង a , b , c ជារង្វាស់ជ្រុងនៃត្រីកោណ ហើយ $p = \dfrac{a+b+c}{2}$ ជាកន្លះបរិមាត្រ

r ជាកាំរង្វង់ចារឹកក្នុងត្រីកោណ និង S ជាផ្ទៃក្រឡារបស់ត្រីកោណ ។

តាមរូបមន្តហេរ៉ុង $S = \sqrt{p(p-a)(p-b)(p-c)} = pr$ ដោយ $r = 1$

គេទាញបាន $(p-a)(p-b)(p-c) = p \quad (1)$

តាង $x = p-a$, $y = p-b$, $z = p-c$ ។

ដោយ $a, b, c \in IN^*$ នោះ $x, y, z \in IN^*$

គេបាន $x + y + z = 3p - (a+b+c) = 3p - 2p = p$

សមីការ (1) អាចសរសេរ $x + y + z = xyz$

សន្មតថា $x > y > z$ នោះ $3x > x + y + z = xyz$ ឬ $y.z < 3$

គេទាញ $y = 2$, $z = 1$ និង $x = 3$ ។

ចំពោះ $x = 3$, $y = 2$, $z = 1$ នោះ $p = x + y + z = 6$

ដូចនេះ $a = 3$, $b = 4$, $c = 5$ ។

ហើយដោយ $a^2 + b^2 = c^2$ នោះត្រីកោណនេះជាត្រីកោណកែង ។

លំហាត់ទី២៩

ចូរបង្ហាញថាបើ $abc = 8$ និង $a, b, c > 0$ នោះគេបាន :

